ធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណកម្មការ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឲ្យបានសម្រេច ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## ២- សេចក្តីសំរេច

*រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៩*

### សេចក្តីសំរេច ០១ សសរ.

### ស្តីពី

### ការប្រគល់ភារកិច្ចដឹកនាំបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស

★★★

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤
- ដើម្បីពង្រឹងប្រសិទ្ធភាព នៃការដឹកនាំបញ្ជា និង ពង្រឹកកងរាជអាវុធហត្ថលើផ្ទៃប្រទេស

### សំរេច

**ប្រការ ១ :** ត្រូវដាក់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ឲ្យស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី ស្របតាមមាត្រា ១ នៃអនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ១៩៩៤ ។

**ប្រការ ២ :** ត្រូវបានប្រគល់ភារកិច្ចជូនឧត្តមសេនីយ៍ឯក ឡៅ បាញ់ ជួសមុខឲ្យនាយករដ្ឋមន្ត្រី ក្នុងការដឹកនាំបញ្ជាជាអចិន្ត្រៃយ៍ និងបំពេញមុខនាទីតាមមាត្រាទី ៧ នៃអនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីអគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។

**ប្រការ ៣ :** ឧត្តមសេនីយ៍ឯក ឡៅ បាញ់ មានសិទ្ធិប្រើប្រាស់ត្រានាយករដ្ឋមន្ត្រី ពេលចេញបញ្ជាដឹកនាំលើកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងបេសកកម្មមានចរិតអន្តរក្រសួង និងមានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ក្នុងនាមអគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។

ប្រការ ៤ : ក្រុមការងារដឹកនាំ ... ដោយមានការ ... ពីទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាសេនាធិការរបស់ ...

ប្រការ ៥ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ ប្រធានអង្គភាពពាក់ព័ន្ធនៃស្ថាប័ន ជាតិគ្រប់ក្រសួង-ស្ថាប័ន ខេត្ត-ក្រុងដែលពាក់ព័ន្ធ និងអគ្គលេខាធិការ ... ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## ៣- បទបញ្ជា

*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៩*

### បទបញ្ជានៃរាជរដ្ឋាភិបាលកម្ពុជា លេខ ០២ បប.

ជូនចំពោះ

- ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តម ឧត្តមសេនីយ៍ឯក នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ
- ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គនាយកនគរបាលជាតិ
- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ក្រុងកែប ក្រុងប៉ៃលិន
- ឯកឧត្តម អភិបាលខេត្ត-ក្រុង

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការកាប់បំផ្លាញព្រៃឈើ និងការដឹកជញ្ជូនឈើ ដោយខុសច្បាប់បានកើតមានជាហូរហែ ធ្វើឱ្យធនធានព្រៃឈើរបស់ជាតិកាន់តែរងការបំផ្លិចបំផ្លាញ និងរិចរិលយ៉ាងធ្ងន់ធ្ងរបំផុត ដែលជាផលប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងបរិស្ថានធម្មជាតិ ដែលជាកេរ្តិ៍មរតកដ៏មានតម្លៃរបស់ជាតិយើង ។

ស្ថិតនៅចំពោះមុខស្ថានភាពប្រកបដោយគ្រោះថ្នាក់ខាងលើនេះ ដើម្បីទប់ស្កាត់ ... និងទប់ស្កាត់ ... ដែលកំពុងកើតមានជាហូរហែ រាជរដ្ឋាភិបាលចេញបទបញ្ជាជូនឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ឯកឧត្តមរដ្ឋមន្ត្រី